# ការពិភាក្សាបន្តអំពីរឿងឯកសារ ៖ ការស្វែងរកដែនកំណត់ជាក់លាក់ណាមួយពាក់ព័ន្ធទៅនឹងករណី០០២ ដំណាក់កាលសវនាការទី១

*ដោយ វ៉េនឌល ឌីហ្សាល់កូ*

*ថ្ងៃទី១៣ ខែមិនា ឆ្នាំ២០១៧*

*ប្រែសម្រួលដោយ ជា ដល្លា*

នៅថ្ងៃអង្គារ៍ ទី១៣ ខែមីនានេះ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាចាប់បន្តដំណើការករណី០០២ទៀត ដែលប្រឆាំងទៅនឹងមេដឹកនាំ នួន ជា, អៀង សារី និង ខៀវ សំផន។ សម្រាប់ដំណើរការនីតិវិធីថ្ងៃនេះនឹងបន្តកិច្ចពិភាក្សាកាលពីថ្ងៃម្សិលមិញទាក់ទងទៅនឹងតួនាទី និងការដាក់បញ្ចូលឯកសារជាក់លាក់ណាមួយដែលស្នើដោយគ្រប់ភាគីទាំងអស់។

## អង្គជំនុំជម្រះបញ្ជាក់នូវអ្វីដែលបានលើកមកនិយាយកាលពីម្សិលមិញ

ថ្ងៃនេះ កិច្ចដំណើរការចាប់ផ្តើមដោយការជំទាស់ផ្ទាល់មាត់ទៅនឹងឯកសារដែលបានដាក់ជូនដោយព្រះរាជអាជ្ញានិងដើមបណ្តឹងរដ្ឋប្បវេណីពីសំណាក់ក្រុមការពារក្តីរបស់ ខៀវ សំផន។ មុននឹងប្រគល់តួនាទីទៅក្រុមការពារក្តី ចៅក្រម និល ណុន បានប្រគល់តួនាទីទៅចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍ ដើម្បីផ្តល់ការណែនាំឲ្យច្បាស់ទៅកាន់ភាគីជាភាសារអង់គ្លេសទាក់ទងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះកាលពីថ្ងៃម្សិលមិញ។ ចៅក្រម ខាតរ៉ាយថ៍ បានបញ្ជាក់ច្បាស់ថា អង្គជំនុំជម្រះបានបញ្ជាក់កាលពីរសៀលម្សិលមិញហើយថា អង្គជំនុំជម្រះនឹងមិនផ្តល់ពេលវេលាដើម្បីពិភាក្សាពីតម្លៃនៃឯកសារទេ តែភាគីទាំងអស់អាចធ្វើការតវ៉ាទាក់ទងទៅនឹងឯកសារក្នុងអំឡុងពេលសវនាការនេះ។ ក្រោយពី លោកស្រីចៅក្រមបញ្ជាក់រួចមក ចៅក្រម និល ណុន បានប្រគល់តួនាទីនេះទៅក្រុមការពារក្តីរបស់ ខៀវ សំផន។

Documentation Center of Cambodia
Searching for the Truth: Memory & Justice ស្វែងរកការពិត ដើម្បីការចងចាំនិងយុត្តិធម៌
66 Preah Sihanouk Blvd. ♦ P.O.Box 1110 ♦ Phnom Penh ♦ Cambodia
t (855-23) 211-875 ♦ f (855-23) 210-358 ♦ dccam@online.com.kh ♦ www.dccam.org

## ក្រុមការពារក្តី ខៀវ សំផន និយាយពីការដាក់បញ្ចូលឯកសារ

មេធាវី គង់ សំអុន បានជំទាស់តាំងនាមឲ្យក្រុមការពារក្តីរបស់ ខៀវ សំផន។ លោកនិយាយម្តងទៀតពាក់ព័ន្ធទៅនឹងករណី០០២ ដំណាក់កាលសវនាការទីមួយកាលពីថ្ងៃម្សិលមិញ ដែលតវ៉ាដោយក្រុមការពារក្តីរបស់ នួន ជា និង អៀង សារី នៅពេលនេះ គង់ សំអុន បានបញ្ជាក់ថាឯកសារណាដែលទាក់ទងទៅនឹងប្រធានបទដូចជា ការងារនៅតាមសហករណ៍ និងការចល័តប្រជាជននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ជាមួយនឹងការចោទប្រកាន់ពីបទប្រល័យពូជសាសន៍គឺមិនពាក់ព័ន្ធទៅនឹងដំណាក់កាលតុលាការដំបូងនេះទេ ហើយករណីនេះមិនត្រូវបានពិភាក្សានៅក្នុងការដាក់បញ្ចូលរបស់ក្រុមការពារក្តីដែរ ។

ស្រដៀងគ្នាទៅនឹងការបកស្រាយរបស់មេធាវីរបស់ អៀង សារី កាលពីម្សិលមិញដែរ មេធាវីការពារក្តីបានបញ្ជាក់ថា ក្រុមការពារក្តីរបស់ ខៀវ សំផន នឹងមិនពិភាក្សាពីឯកសារទាក់ទងនឹងអតីតជនជាប់ចោទ អៀង ធីរិទ្ធ ទេព្រោះភ័ស្តុតាងនោះមិនមានការពាក់ព័ន្ធគ្នា ដោយសារតែជនជនជាប់ចោទរូបនេះមិនមានកាយសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមក្នុងដំណើរការតុលាការនេះ ។

មេធាវី គង់ សំអុន បន្តទៀតថា ក្រុមការពារក្តីមិនចង់ធ្វើការផ្តល់យោបល់ទៅលើឯកសារ «ថ្មី» ជាង៣០០ឯកសារដែលបានដាក់បញ្ចូលនៅក្នុងសំណុំឯកសារនោះទៀតទេ ហើយមេធាវីបានស្នើថា អង្គជំនុំជម្រះគួរតែអនុញ្ញាតឲ្យភាគីទាំងអស់ពិភាក្សាពីឯកសារនេះនាដំណាក់កាលក្រោយមកទៀត ។

បន្ទាប់មក មេធាវី គង់ សំអុន បានយល់ស្របជាមួយក្រុមការពារក្តីរបស់ អៀង សារី ដោយស្នើទៅអង្គជំនុំជម្រះថា រាល់សាក្សីដែលចូលមកធ្វើសក្ខីកម្មទាក់ទងទៅនឹងតួនាទីរបស់ជនជាប់ចោទគួរតែចូលមកធ្វើសក្ខីកម្មដោយផ្ទាល់នៅអង្គជំនុំជម្រះ ជាជាងគ្រាន់តែយកអត្ថបទសម្ភាសន៍មក ។ ក្រោយមក មេធាវីបានប្រគល់តួនាទីនេះទៅសហការីថ្មីរបស់លោកម្នាក់ឈ្មោះ អាន់តា ហ៊្គីស ដើម្បីនិយាយបន្ត។ មេធាវីអន្តរជាតិ អាន់តា ហ៊្គីស បានគូសបញ្ជាក់ថា ក្រុមការពារក្តីរបស់ នួន ជា និង អៀង សារី បានបកស្រាយដោយ«ភាពឆ្លាតវាងវៃ» ហើយលោកស្រីនឹងបកស្រាយដោយមិនឲ្យជាន់គ្នាទៅនឹងអ្វីដែលមេធាវីការពារក្តីទាំងពីរក្រុមបាននិយាយរួចហើយទេ ។ លោកស្រីបានលើកអំពីប្រធានបទ«ប្រវត្តិរូប» ដែលបានដាក់ជូនដោយភាគីព្រះរាជអាជ្ញា ។

ដំបូង មេធាវី អាន់តា ហ៊្គីស បានលើកយកមកនិយាយឡើងវិញទាក់ទងទៅនឹងការរក្សាទុកឯកសារទាំងអស់នេះ ដែលធ្លាប់បាននិយាយរួចមកហើយក្នុងអំឡុងពេលសវនាការមុនៗ ។ មេធាវី អាន់តា ហ៊្គីស បានអះអាងថា សម្រាប់ឯកសាររបស់កម្ពុជាប្រជាធិបតេយ្យក្នុងរយៈកាលស្រដៀងគ្នា

នេះ ប្រភពឯកសារនៅតែមានសភាពមិនច្បាស់លាស់ដដែល ដែលធ្វើឲ្យមានការ«ចង់ដឹង»ពីភាពទុកចិត្ត ទៅលើឯកសារ នោះកាន់តែខ្លាំងជាងមុន ។

លោកស្រី ក៏ជំទាស់ទៅនឹងរបាយការណ៍ដែលមានលក្ខណៈវិភាគមួយចំនួនដែលសរសេរដោយ អ្នកស្រាវជ្រាវពីសម័យខ្មែរក្រហម ហើយសព្វថ្ងៃធ្វើការនៅអង្គជំនុំជម្រះនេះគឺ ក្រេក អេចឆេសាន់ ។ ទាក់ទងទៅនឹងអ្វីដែលហៅថា ជា«របាយការណ៍ពាណិជ្ជកម្ម»ពីរបបកម្ពុជាប្រជាធិបតេយ្យ អានតា ហ្គីស បានបញ្ជាក់ថា ការរក្សាទុកឯកសារនៅតែមាន «ការសង្ស័យដដែល» ។ លោកស្រី បានបញ្ជាក់បន្ថែមទៀតអំពីការជំទាស់របស់ក្រុមការពារក្តីរបស់ ខៀវ សំផន ដែលប្រមូលដោយ មជ្ឈមណ្ឌលឯកសារកម្ពុជា ។ មេធាវី អានតា ហ្គីស ក៏បានបញ្ជាក់ដែរថា ចំណារដែលសរសេរដោយ ដៃមាននៅលើឯកសារពាណិជកម្មជាច្រើន ហើយចំណារនោះមិនទាន់មានការពន្យល់ឲ្យបានគ្រប់គ្រាន់ និងកំណត់ឲ្យច្បាស់នៅឡើយទេ ។

បន្ទាប់មក លោកស្រីមេធាវី បានចូលរួមការជំទាស់ដូចក្រុមការពារក្តីទាំងពីរដែរទាក់ទងទៅនឹង កិច្ចការនៅសហករណ៍ក្នុងស្រុកត្រាំកក់ ។ ជាពិសេស លោកស្រីបានអះអាងថា ឯកសារនោះមិនពាក់ព័ន្ធទៅនឹងករណី០០២ដំណាក់កាលទីមួយនេះទេ ហើយឯកសារខ្លះគឺជាឯកសារថតចម្លងចេញពីឯកសារដើម មិនដឹងថាឯកសារដើមនៅទីណា ។ ទីបញ្ចប់ មេធាវី អានតា ហ្គីស បានទទូចឲ្យអង្គជំនុំជម្រះ មិនរាប់បញ្ចូលឯកសារទាំងអស់នោះចូលជាភស្តុតាង ។

លោកស្រីក៏បានបញ្ជាក់បន្ថែមទៀតថា ការចម្រាញ់យកព័ត៌មានតាមរយៈការធ្វើទារុណកម្មគឺ មិនអាចទទួលយកបានទេ ដូចអ្វីដែលមេធាវីរបស់ ខៀវ សំផន ធ្លាប់ជំទាស់រួចមកហើយ ហើយ មេធាវី អានតា ហ្គីស បានបញ្ជាក់ថា ឯកសារនេះមិនមានការពាក់ព័ន្ធទៅនឹងករណី០០២ នាដំណាក់ កាលទីមួយទេ ។

មេធាវី អានតា ហ្គីស បានស្នើឲ្យដកឯកសារសម្ភាសន៍ពីករណី០០១ដែលព្រះរាជអាជ្ញាចង់ ប្រើប្រាស់ក្នុងករណី០០២ដែលឯកសារនោះជាប់ពាក់ព័ន្ធទៅនឹងបទឧក្រិដ្ឋដែលបានកើតឡើងនៅមន្ទីរស -២១ ។ បន្ទាប់មក លោកស្រីបានលើកពី«ចំណុចសំខាន់»ដែលអង្គជំនុំជម្រះបានសម្រេចរួច ហើយ ត្រង់ថា ប្រធានបទទាក់ទងទៅនឹងការអប់រំ ការធ្វើការតាមសហករណ៍គឺ មិនត្រូវយកមកប្រើប្រាស់ក្នុង ករណី០០២ ដំណាក់កាលទីមួយនេះទេ ។ ដូច្នេះ មេធាវី អានតា ហ្គីស បានអះអាងថា ឯកសារ ដែលយកមកពីប្រទេសវៀតណាមក៏មិនបានចងក្រងតាមបែបវិទ្យាសាស្ត្រដែរ ហើយឯកសារនេះគួរតែ ពិនិត្យមើលឲ្យបានច្បាស់ជាមុនសិន ។ ជាមួយគ្នានោះ លោកស្រីក៏បានជំទាស់ទៅនឹងការប្រើប្រាស់

វីដេអូ ដូចអ្វីដែលមេធាវីរបស់ អៀង សារី បានទាមទារដែរកាលពីម្សិលមិញទាក់ទងទៅនឹងការខ្វះព័ត៌មានអំពីដំណើរការបង្កើតវីដេអូនេះនិងអំពីគំនិតនៃអ្នកផលិតខ្សែភាពយន្តនេះ ។

មេធាវី អានតា ហ្គីស បានងាកមកបកស្រាយពីគោលការណ៍របស់ក្រុមការពារក្ដីនៃកង្វះនូវភាពពាក់ព័ន្ធនៃឯកសារដែលដាក់ជូនដោយភាគីព្រះរាជអាជ្ញា ។ បញ្ហានៃឯកសារដែលមិនពាក់ព័ន្ធទៅនឹងសំណុំរឿងនេះត្រូវបានលើកមកនិយាយដោយក្រុមការពារក្ដីទាំងបីដោយបានអះអាងថា ព្រះរាជអាជ្ញាកំពុងតែបញ្ចូលភ័ស្តុតាងបទឧក្រិដ្ឋក្រៅពីវិសាលភាពដែនកំណត់នៃដំណាក់កាលទីមួយនេះ ។

បន្ទាប់មក លោកស្រីបានជំទាស់ទៅនឹងបទសម្ភាសន៍ដែលធ្វើឡើងដោយអ្នកសារព័ត៌មាន មិនស្គាល់ឈ្មោះ និងប្រមូលដោយមជ្ឈមណ្ឌលឯកសារកម្ពុជា និងសាស្ត្រាចារ្យ ប៉ែន យៀវនិន និងខ្សែវីដេអូដែលថតឡើងដោយក្រុមអាល្លឺម៉ង់ក្នុងប្រទេសកម្ពុជាក្នុងឆ្នាំ១៩៧៩ ក្រោយពីក្រុមនោះត្រូវបានអញ្ជើញដោយអជ្ញាធរវៀតណាមដែលគ្រប់គ្រងប្រទេសកម្ពុជា ។

មេធាវី អានតា ហ្គីស បានរៀបរាប់ម្ដងហើយម្ដងទៀតនូវអ្វីដែលធ្វើឡើងដោយក្រុមការពារក្ដីរបស់ អៀង សារី ទាក់ទងទៅនឹងភាពទុកចិត្តបានរបស់ឯកសារបកប្រែនិងអត្ថបទស្រាវជ្រាវ ដែលសរសេរឡើងដោយជនបរទេស និងអត្ថបទសង្ខេបពីវិទ្យុរបស់បក្សកុម្មុយនីស្តកម្ពុជាក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ លោកស្រីបានបញ្ជាក់ទៀតថា ចំពោះឯកសារដែលសរសេរដោយអ្នកនិពន្ធភាគីទីបីអត្តសញ្ញាណរបស់អ្នកនិពន្ធនោះមិនដឹងច្បាស់ទេ ហើយព័ត៌មាននៅក្នុងអត្ថបទស្រាវជ្រាវនោះនៅតែមិនទាន់បញ្ជាក់ឲ្យច្បាស់ដែរ ។

មេធាវីការពារក្ដីរបស់ ខៀវ សំផន ក៏ជំទាស់ទៅនឹងអត្ថបទស្រាវជ្រាវដោយអ្នកនិពន្ធមួយចំនួនដូចជា ក្រេក អេចឆេសាន់ ជាដើម ។ មេធាវី អានតា ហ្គីស បានស្នើទៅអង្គជំនុំជម្រះឲ្យលើកពីប្រធានបទមួយដែលក្រុមការពារក្ដីរបស់ អៀង សារី បានលើកយកមកនិយាយរួចហើយដែលថាអត្ថបទស្រាវជ្រាវរបស់ ក្រេក អេចឆេសាន់ បានធ្វើសេចក្ដីសន្និដ្ឋានជាច្រើនដោយមិនបានផ្ទៀងផ្ទាត់ឲ្យច្បាស់លាស់ទៅនឹងអ្វីដែលបានសម្ភាសន៍និងតាមភ័ស្តុតាងត្រឹមត្រូវទេ ហើយអ្នកនិពន្ធអាចប្រើប្រាស់ព័ត៌មានដែលទទួលបានតាមរយៈការធ្វើទារុណកម្ម ។ លោកស្រីបានបញ្ជាក់ទៀតថា ប្រសិនបើព្រះរាជអាជ្ញានៅតែទទូចចង់ប្រើប្រាស់របាយការណ៍ទាំងនោះទៀត ក្រេក អេចឆេសាន់ គួរតែត្រូវបានកោះហៅដើម្បីឡើងមកធ្វើសក្ខីកម្មទាក់ទងទៅនឹង«ផលលំបាកមួយចំនួន» ដែលមាននៅក្នុងរបាយការណ៍ ឬអត្ថបទស្រាវជ្រាវនោះ ។

មេធាវី អានតា ហ្គីស បានបញ្ចប់ដោយធ្វើការកត់សម្គាល់មួយចំនួនទាក់ទងទៅនឹងឯកសារដែលបានដាក់ជូនដោយភាគីដើមបណ្ដឹងរដ្ឋប្បវេណី ។ លោកស្រីបានអះអាងថា ឯកសារចំនួនប្រាំបួន

ក្នុងចំណោមឯកសារចំនួនដប់មិនមានការពាក់ព័ន្ធនៅក្នុងសំណុំរឿង០០២ ដំណាក់កាលសវនាការទីមួយនេះទេ។ ចំណែកឯកសារផ្សេងទៀតដែលសរសេរដោយសាស្រ្តាចារ្យ ប៉ែន យៀវនិន នៅពេលដែលគាត់មានអាយុ២១ឆ្នាំ មេធាវី អានតា ហ្គីស បានឲ្យដឹងថា អត្ថបទស្រាវជ្រាវរបស់សិស្សមិនគួរយកមកប្រើប្រាស់ទេ ហើយអត្ថបទនោះមានលក្ខណៈស្រាលពេក គ្មានទម្ងន់អ្វីទេ។

## ក្រុមការពារក្តីធ្វើសេចក្តីសន្និដ្ឋានបញ្ចប់ ហើយ អៀង សារី សុំទៅសម្រាកនៅបន្ទប់សោធទស្សន៍

ក្រុមការពារក្តីរបស់ ខៀវ សំផន បានបញ្ចប់ការតវ៉ារបស់ខ្លួន ហើយអង្គជំនុំជម្រះប្រកាសសម្រាកនៅពេលព្រឹក។ តែមុននឹងសម្រាក ចៅក្រម និល ណុន បានអនុញ្ញាតឲ្យ អៀង សារី ទៅតាមដានដំណើរការនៅបន្ទប់សោធទស្សន៍វិញដូចសព្វដង។

## ភាគីព្រះរាជអាជ្ញាធ្វើការឆ្លើយតបទៅនឹងការជំទាស់របស់ក្រុមការពារក្តី

ក្រោយពីសម្រាកនៅពេលព្រឹក អង្គជំនុំជម្រះបានប្រគល់តួនាទីនេះទៅភាគីព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណីដើម្បីជំទាស់ទៅនឹងឯកសារដែលបានដាក់ជូនដោយភាគីការពារក្តី។ តែទាំងភាគីព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណីមិនធ្វើការជំទាស់ណាមួយទៅនឹងឯកសារដែលក្រុមការពារក្តីដាក់ជូនទេ។ ដូច្នេះ អង្គជំនុំជម្រះនៅតែបន្តផ្តល់ពេលវេលាមួយចំនួនដើម្បីឆ្លើយតបទៅនឹងការជំទាស់ដែលលើកឡើងដោយភាគីការពារក្តីកាលពីម្សិលមិញនិងកាលពីព្រឹកនេះ។

មេធាវីប្រឹក្សារបស់ភាគីព្រះរាជអាជ្ញាឈ្មោះ វ៉ីង ហ្គូត ចាប់ផ្តើមឆ្លើយតបទៅនឹងការជំទាស់ដែលលើកឡើងដោយក្រុមការពារក្តីដោយអានវិធានផ្ទៃក្នុង៨៧របស់អង្គជំនុំជម្រះ ទាក់ទងទៅនឹងការដាក់បញ្ចូលភស្តុតាងដែលនិយាយអំពីការកំណត់នៃការដាក់បញ្ចូលឯកសារ។ លោកមេធាវីបានអះអាងថា ការរៀបរាប់ហេតុផលជាហូហែររបស់ក្រុមការពារក្តីក្នុងការព្យាយាមដកឯកសារចេញត្រូវបានរៀបរាប់នៅក្នុងវិធាន៨៧(៣)យ៉ាងល្អិតល្អន់ហើយ ហើយក៏ស្របតាមវិធានច្បាប់អន្តរជាតិដែរ។ លោកបានអះអាងថា មានតែ«បទដ្ឋានអតិបរមានៃភាពជឿទុកចិត្តនិងការពាក់ព័ន្ធនៃឯកសារ»ប៉ុណ្ណោះដែលតម្រូវឲ្យមាន។ ក្រោយមក លោកមេធាវី វ៉ីង ហ្គូត បានរៀបរាប់ដោយសង្ខេបទាក់ទងទៅនឹងការឃើញជាលើកដំបូងដោយបញ្ជាក់ពីភាពទុកចិត្តនិងភាពពាក់ព័ន្ធក្នុងការដាក់បញ្ចូលភស្តុតាង។

បន្ទាប់មក លោកមេធាវីបានអះអាងថា បញ្ហាជាច្រើនទាក់ទងទៅនឹងឯកសារដែលលើកឡើងដោយក្រុមការពារក្តីគឺដើម្បីដកឯកសារចេញ ជាជាងដាក់បញ្ចូលឯកសារចូល។ លោកបានបញ្ជាក់

ទៀតថា អង្គជំនុំជម្រះបានបកស្រាយហើយថា ឯកសារថតចម្លងនឹងត្រូវយកមកប្រើប្រាស់ជំនួសឯកសារដើម ។ ទាក់ទងទៅនឹងឯកសារដែលមានប្រភពមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា លោកមេធាវីបានឲ្យដឹងថា អ្នកតំណាងមកពីមជ្ឈមណ្ឌលឯកសារកម្ពុជាពីរនាក់បានចូលខ្លួនមកធ្វើសក្ខីកម្មរួចហើយ ដើម្បីរៀបរាប់ពីការចងក្រងឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាដែលប្រមូលឯកសារទាក់ទងទៅនឹងរបបខ្មែរក្រហម ។ លោកបានបន្តទៀតថា ព្រះរាជអាជ្ញាបានបញ្ជាក់ហើយអំពីភាពដែលអាចទុកចិត្តបាន និងការជឿជាក់លើឯកសារ ដែលបានដាក់បញ្ចូលរួចហើយ ។ លោកមេធាវី វើង ហួត បានបញ្ជាក់ថា នេះគឺជាការពិតនៃបទដ្ឋាន«ការវាយតម្លៃឯកសារដោយសេរី» ដែលបានអនុវត្តដោយយោងតាមប្រព័ន្ធច្បាប់«ស៊ីវិលឡូ» របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

បន្ទាប់ពីនិយាយទាក់ទងទៅនឹងការដាក់បញ្ចូលឯកសារចប់ លោកមេធាវី វើង ហួត បានលើកពីប្រភេទភស្តុតាងជាក់លាក់មួយចំនួនរួមមាន ឯកសារដែលមានអាយុប្រហាក់ប្រហែលគ្នាក្នុងរបបខ្មែរក្រហម ។ ក្នុងអំឡុងពេលនៃការដាក់បញ្ចូលឯកសារនេះ លោកបានបញ្ជាក់ថា ដំណាក់កាលនៃការប្រមូលឯកសារដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គឺត្រូវស្អេនជាពណ៌ធម្មជាតិរាល់ឯកសារពីមន្ទីរស-២១ ដោយអ្នកស៊ើបអង្កេតតុលាការ ។

ទាក់ទងទៅនឹងឯកសារពីបណ្ណសារដ្ឋានជាតិ លោកមេធាវី វើង ហួត បានបញ្ជាក់ថា ឯកសារជាច្រើនរួមមាន ឯកសារពាណិជ្ជកម្មពីរបបកម្ពុជាប្រជាធិបតេយ្យ ។ ដោយនិយាយហើយនិយាយទៀត និងនិយាយពីអ្វីដែលលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាបាននិយាយរួចហើយ លោកបាននិយាយអំពីសញ្ញាណដោយស្នើថា ឯកសារទាំងអស់នោះគឺជាឯកសាររបស់កម្ពុជាប្រជាធិបតេយ្យយ៉ាងពិតប្រាកដ ។

មុននឹងធ្វើការសន្និដ្ឋានទៅនឹងការជំទាស់ចំពោះមេធាវីការពារក្តី វើង ហួត បានឆ្លើយតបទៅនឹងអ្វីដែលមេធាវី ម៉ៃឃើល ខាណាវ៉ាស បានបញ្ជាក់កាលពីម្សិលមិញថា ព្រះរាជអាជ្ញាកំពុងតែព្យាយាម «លួចបញ្ចូល»ឯកសារ ។ លោកមេធាវី បានបញ្ជាក់នូវការជំទាស់ទាំងស្រុង តាងនាមឲ្យព្រះរាជអាជ្ញាចំពោះសំណើរបស់ព្រះរាជអាជ្ញា ហើយថា ភាគីព្រះរាជអាជ្ញាមិនបាន«លួចបញ្ចូល»ភស្តុតាងនៅចំពោះមុខតុលាការទេ តែព្រះរាជអាជ្ញាបានស្នើមើលឯកសារទាំងអស់តាមរយៈបទដ្ឋាននៃការបញ្ចូលភស្តុតាងរបស់អង្គជំនុំជម្រះ ។

បន្ទាប់មក លោកមេធាវី វើង ហួត បានប្រគល់តួនាទីនេះទៅមេធាវីប្រឹក្សាអន្តរជាតិឈ្មោះ ថារីក អាប់ឌុលហាក់ នឹងមកនិយាយដើម្បីឆ្លើយតបទៅនឹងអ្វីដែលបានស្នើដោយមេធាវី ខាណាវ៉ាស ។ ថារីក អាប់ឌុលហាក់ បានចាត់ទុកសំណើរបស់មេធាវី ខាណាវ៉ាស ថាមិនមានភាពត្រឹមត្រូវទេដែល

និយាយថា ព្រះរាជអាជ្ញាព្យាយាមកាត់ទោសករណី០០២ជាមួយនឹងឯកសារដែលខ្លួនយល់ថាមានការទុកចិត្តបាន ព្រមទាំងការសំអាងរបស់មេធាវី ខាណាវ៉ាស ទាក់ទងទៅនឹងក្រមសីលធម៌វិជ្ជាជីវៈរបស់ភាគីព្រះរាជអាជ្ញា ។ ថារីក អាប់ឌុលហាក់ បានកត់សម្គាល់ថា ព្រះរាជអាជ្ញាបានបញ្ជូនបញ្ជីឈ្មោះអ្នកដែលនឹងត្រូវយកមកធ្វើជាសាក្សីទៅកាន់អង្គជំនុំជម្រះរួចហើយ ដោយក្នុងបញ្ជីនោះមានមនុស្សចំនួនជាង៣០០នាក់ ហើយព្រះរាជអាជ្ញាបានជម្រាបហើយថា ខ្លួននឹងប្រើសាក្សីផងនិងភស្តុតាងផងក្នុងអំឡុងពេលនៃដំណើរការសវនាការនោះ ។

ក្រោយមក ថារីក អាប់ឌុលហាក់ បានពិភាក្សាអំពីសេចក្តីបង្គាប់របស់អង្គជំនុំជម្រះដែលបានបែងចែកសវនាការក្នុងករណី០០២ជាច្រើនដំណាក់កាល ។

យោងតាមព្រះរាជអាជ្ញា គ្រប់ភាគីទាំងអស់បានដាក់ភស្តុតាងទៅកាន់អង្គជំនុំជម្រះរួចហើយ ។ ម្យ៉ាងវិញទៀត ថារីក អាប់ឌុលហាក់ បានបន្ថែមទៀតថា ក្រុមការពារក្តីដែលបានលើកសរសើរដល់ដីការបស់តុលាការនិងមិនបានជំទាស់ទៅនឹងការប្រើប្រាស់ឯកសារណាមួយទេ ហើយពេលនេះ ភាគីការពារក្តីមិនអាចប្រើប្រាស់ហេតុផលណាមួយ ដើម្បីដកភស្តុតាងចេញនូវឯកសារដែលដាក់ជូនដោយព្រះរាជអាជ្ញាទេ ។ ថារីក អាប់ឌុលហាក់ បានបញ្ចប់ដោយអះអាងចុងក្រោយថា ដំណាក់កាលសវនាការ០០២ ត្រូវបានតាក់តែងឡើងដោយអង្គជំនុំជម្រះ ដើម្បីបង្កើតនូវហេតុការណ៍ពាក់ព័ន្ធទៅនឹងបទចោទប្រកាន់ទាំងអស់ដែលបានសរសេរនៅក្នុងដីការដំណោះស្រាយ ហើយព្រះរាជអាជ្ញាគួរតែត្រូវបានអនុញ្ញាតបញ្ចូលភស្តុតាងពាក់ព័ន្ធទៅនឹង«សហឧក្រិដ្ឋកម្មរួម» ទៅនឹងបទចោទប្រកាន់ទាំងអស់ក្នុងករណី០០២ ។ លោកបានអះអាងថា ព្រះរាជអាជ្ញាបាននាំយកឯកសារដែល«ពាក់ព័ន្ធ»ទៅនឹងសហឧក្រិដ្ឋកម្មរួមដោយភ្ជាប់ទៅនឹងបទឧក្រិដ្ឋដែលបានចោទប្រកាន់ ហើយក៏បានបញ្ជាក់ដែរថា ជាភារកិច្ចរបស់ព្រះរាជអាជ្ញាក្នុងការបង្ហាញបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិជាក់លាក់ណាមួយនៅក្នុងវង្វង់ករណី០០២នាដំណាក់កាលសវនាការទីមួយនេះ ហើយសហឧក្រិដ្ឋរួមត្រូវបានប្រព្រឹត្តិឡើងជាផ្នែកមួយនៃ«ការវាយប្រហារដោយប្រព័ន្ធនិងទូលំទូលាយប្រឆាំងនឹងប្រជាជនស៊ីវិល» ។

ដើម្បីបញ្ជាក់ឲ្យច្បាស់ពីចំណុចនេះ ថារីក អាប់ឌុលហាក់ បានបង្ហាញឯកសារមួយដែលជាសុន្ទរកថារបស់ ប៉ុល ពត ដែលពន្យល់ពីហេតុផលដែលបក្សកុម្មុយនីស្តកម្ពុជាសម្រេចជម្លៀសប្រជាជនទីក្រុងភ្នំពេញក្នុងឆ្នាំ១៩៧៥ ។ សុន្ទរកថានោះបានបញ្ជាក់ថា សេចក្តីសម្រេចក្នុងការជម្លៀសទីក្រុងភ្នំពេញត្រូវបានធ្វើឡើងក្នុងខែកុម្ភៈ ឆ្នាំ១៩៧៥ និងដោយផ្អែកលើតម្រូវការក្នុងការ«កម្ទេច» និងក្រោយមកបំបែកក្រុមសត្រូវឲ្យទៅនៅទីជនបទក្នុងគោលបំណងបំផ្លិចបំផ្លាញសត្រូវទាំងអស់នោះ ។

## នួន ជា ហត់នឿយនិងចង់ទៅសម្រាក បន្ទាប់ពីសម្រាកអាហារថ្ងៃត្រង់

ត្រង់ចំណុចនេះ អង្គជំនុំជម្រះត្រៀមនឹងប្រកាសសម្រាកដូចសព្វដង ហើយ នួន ជា ក៏ធ្វើសំណើជាប្រពៃណីរបស់ខ្លួន ដើម្បីស្នើទៅចៅក្រមទៅសម្រាកដោយសារតែបញ្ហាសុខភាពរបស់គាត់ ។ ដូចសព្វដងដែរ ចៅក្រម និល ណុន បានយល់ព្រមទៅនឹងសំណើនេះ តែសុំឲ្យជនជាប់ចោទប្រគល់លិខិតជាលាយលក្ខណ៍អក្សរមកអង្គជំនុំជម្រះ ។

## ភាគីព្រះរាជអាជ្ញាបន្តឆ្លើយតបទៅនឹងភាគីការពារក្តីដើម្បីការពារការជំទាស់ទៅនឹងឯកសារ

ក្រោយពីសម្រាកអាហារថ្ងៃត្រង់ ថារីក អាប់ឌុលហាក់ បន្តឆ្លើយតបក្នុងនាមព្រះរាជអាជ្ញា ដើម្បីឆ្លើយតបទៅនឹងការជំទាស់របស់ភាគីការពារក្តី ។ ថារីក អាប់ឌុលហាក់ បានចាប់ផ្តើមនិយាយម្តង ហើយម្តងទៀតចំពោះពាក្យ “សវនាការតូច” ដោយក្រុមការពារក្តីដោយពាក្យនេះគឺចង់សំដៅទៅលើករណី០០២ ដំណាក់កាលទីមួយនេះ ។ ថារីក អាប់ឌុលហាក់ បានបញ្ជាក់ថា ការប្រើប្រាស់ពាក្យនេះមិនមានលក្ខណៈត្រឹមត្រូវទេសម្រាប់ជនរងគ្រោះរាប់លាននាក់ ហើយលោកបានទទូចទៅព្រះរាជអាជ្ញាថាមិនត្រូវប្រើពាក្យបែបនេះទេ ។

ក្រោយមក ថារីក អាប់ឌុលហាក់ បង្វែរប្រធានបទដើម្បីឆ្លើយតបទៅនឹងអ្វីដែលភាគីការពារក្តីបាននិយាយទាក់ទងទៅនឹងភ័ស្តុតាងអំពី“សកម្មភាពនិងការប្រព្រឹត្តិ”របស់ជនជាប់ចោទ ។ ថារីក អាប់ឌុលហាក់ បាននិយាយថា នៅឯតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី មានការស្មានជាទូទៅមួយនៃការដាក់បញ្ចូលឯកសារស្រដៀងគ្នាទៅនឹងអ្វីដែលអង្គជំនុំជម្រះកំពុងធ្វើដូច្នេះដែរ ជាធម្មតា តុលាការ គឺមានលក្ខណៈចម្រុងចម្រាសដែលជារឿងធម្មតា ហើយគ្រប់ភាគីទាំងអស់ជាអ្នកធ្វើការស៊ើបអង្កេត មិនដូចច្បាប់ស៊ីវិលឡរបស់អង្គជំនុំជម្រះទេ ។ នេះហើយគឺជាមូលហេតុដែលតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវីក្នុងរឿងក្តី ហ្គាលីក បានបញ្ជាក់ថា វិធានរបស់តុលាកាព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវីបានដកចេញនូវ“អ្វីដែលសាក្សីបាននិយាយ” មិនឲ្យចូលទៅក្នុងសំណុំរឿង ។

លើសពីនោះទៀត ថារីក អាប់ឌុលហាក់ បានបន្តថា ពាក្យថា “អ្វីដែលសាក្សីបាននិយាយ” ត្រូវបានបកស្រាយដោយតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវីថា ជាសេចក្តីថ្លែងដែលត្រូវបានដាក់បញ្ចូលជាផ្លូវការដោយអ្នកមានអំណាចស៊ើបអង្កេត ហើយថា សេចក្តីថ្លែងការណ៍ដូច្នេះត្រូវបានស្មានថា មិនត្រូវដាក់បញ្ចូលនៅតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវីទេ នៅពេលដែលនិយាយអំពីសកម្មភាព និងទង្វើឧក្រិដ្ឋរបស់ជនជាប់ចោទព្រោះការផ្តល់សក្ខីកម្មផ្ទាល់មាន

លក្ខណៈល្អជាង ។ ថាវីក អាប់ឌុលហាក់ បានអះអាងថា សៀវភៅនិងរបាយការណ៍ដែលមានលក្ខណៈវិភាគមិនមែនចាត់ចូលក្នុង "អ្វីដែលសាក្សីបាននិយាយ" ទេ ដូច្នេះឯកសារប្រភេទនេះអាចដាក់ចូលបាននៅពេលនិយាយពីសកម្មភាពនិងទង្វើឧក្រិដ្ឋរបស់ជនជាប់ចោទ ។

បន្ទាប់មក ថាវីក អាប់ឌុលហាក់ ពិភាក្សាអំពីបញ្ហាចម្លើយសារភាពនិងការដាក់បញ្ចូលឯកសារប្រភេទនេះ ដោយសារឯកសារនេះត្រូវបានធ្វើឡើងដោយសារអំពើទារុណកម្មក្រោមច្បាប់អន្តរជាតិ ។ ថាវីក អាប់ឌុលហាក់ បានស្នើថា អង្គជំនុំជម្រះគួរតែបន្តដំណើរទៅមុខទៀតដោយប្រើប្រាស់ចម្លើយសារភាពបើសិនជាត្រូវការប្រើ ហើយអង្គជំនុំជម្រះអាចយកមកប្រើតាមស្ថានភាពជាក់ស្តែង ។ លោកនៅរក្សាជំហរថា មិនមានការហាមឃាត់ទូទៅណាមួយអំពីភស្តុតាង "ដែលទទួលបានតាមរយៈការធ្វើទារុណកម្មទេ" តែនេះជាបែបបទក្រោមអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម ក្នុងការដាក់បញ្ចូលភស្តុតាងនៅពេលដែលឯកសារនោះទទួលបានតាមរយៈទារុណកម្ម ។

ទាក់ទងទៅនឹងឯកសារដែលក្រុមការពារក្តីរបស់ ខៀវ សំផន បញ្ជាក់ថា "ថ្មី" ថាវីក អាប់ឌុលហាក់ បានអះអាងថា ឯកសារទាំងនេះត្រូវបានដាក់បញ្ចូលនៅចំពោះមុខតុលាការតាំងពីដំណាក់កាលដំបូងមកម៉្លេះ ។ ក្រោយមក លោកបានងាកមកបកស្រាយនូវការចោទប្រកាន់ដោយក្រុមការពារក្តី ខៀវ សំផន ថាមានភាពលម្អៀងជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ថាវីក អាប់ឌុលហាក់ បានបញ្ជាក់ថា ក្រុមការពារក្តីរបស់ នួន ជា បានបោះបង់ចោលការចោទប្រកាន់ថាមានភាពលម្អៀងជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជារួចទៅហើយ តាំងពីនាយក ឆាំង យុ ចូលមកធ្វើសក្ខីកម្មមក ។

ថាវីក អាប់ឌុលហាក់ បានអះអាងទៀតថា ឯកសារមកពីមជ្ឈមណ្ឌលឯកសារកម្ពុជាមិនមែនប្រមូលបានដោយបញ្ហាអ្វីមួយនោះទេ ហើយស្ថាប័ននេះបានផ្តល់ឯកសារជូនទៅគ្រប់ភាគីទាំងអស់ និងចំពោះសាធារណជនទូទៅ ។ លោកនៅតែរក្សាជំហរថា គោលបំណងរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាគឺដើម្បីស្វែងរកយុត្តិធម៌ និងការទទួលខុសត្រូវសម្រាប់ការធ្វើទុក្ខបុកម្នេញកាលពីរបបខ្មែរក្រហម ហើយភស្តុតាងនោះមិនមានបញ្ហាអ្វីទេ ។

ទាក់ទងទៅនឹងបញ្ហានៃការរក្សាទុកឯកសារជាក់លាក់ណាមួយ ជាពិសេសឯកសារ "ពាណិជ្ជកម្ម" របស់កម្ពុជាប្រជាធិបតេយ្យ ថាវីក អាប់ឌុលហាក់ បានបញ្ជាក់ថា វាមិនចាំបាច់ទេដែលភាគីនីមួយៗត្រូវដាក់បញ្ចូលភស្តុតាងដើម្បីបង្កើតជាប្រព័ន្ធនៃឯកសារនោះ ។ លោកក៏បានបញ្ជាក់ដែរថា អ្នកស៊ើបអង្កេតរបស់អង្គជំនុំជម្រះបានថតចម្លងពីឯកសារដើមជាច្រើនមកពីមន្ទីរស-២១ ។ ទាក់ទងទៅនឹងព័ត៌មានដែលមាននៅក្នុងប្រភេទឯកសារពាណិជ្ជកម្ម ថាវីក អាប់ឌុលហាក់ បានបង្ហាញឯកសារមួយដើម្បីបញ្ជាក់ពីតម្លៃនៃប្រភពរបស់ឯកសារព័ត៌មានអំពីការគ្រប់គ្រងវិស័យកសិកម្ម ជាពិសេសដំណាំស្រូវក្នុង

របបកម្ពុជាប្រជាធិបតេយ្យ ហើយជនជាប់ចោទ ខៀវ សំផន តែងតែទទួលរបាយការណ៍បែបនេះយ៉ាងទៀងទាត់ ។ ឯកសារទាក់ទងទៅនឹងផលិតផលកសិកម្មនិងការដឹកជញ្ជូនស្រូវក្នុងរបបកម្ពុជាប្រជាធិបតេយ្យត្រូវបានបញ្ជូនទៅគណៈមជ្ឈិមរបស់បក្សកុម្មុយនីស្តកម្ពុជា ។

ថាវីក អាប់ឌុលហាក់ បានអះអាងទៀតថា ឯកសារដូចជារូបថត ផែនទី និងរបាយការណ៍ផ្សេងទៀតសុទ្ធតែមានការពាក់ព័ន្ធសម្រាប់ករណី០០២នេះ ហើយគួរតែដាក់បញ្ចូលដោយអង្គជំនុំជម្រះហើយចៅក្រមអាចវាយតម្លៃពីទម្ងន់របស់ភស្តុតាងបែបនេះ ។ ទាក់ទងទៅនឹងសៀវភៅ ព្រះរាជអាជ្ញាបានបកស្រាយថា អ្នកនិពន្ធសៀវភៅមិនចាំបាច់ទាល់តែមកធ្វើសក្ខីកម្មទេ ដោយសារតែសៀវភៅនោះមិនមែនជា“ភស្តុតាងសំខាន់នៃសកម្មភាពរបស់ជនជាប់ចោទទេ” ។

ក្រោយពីសម្រាកនៅពេលរសៀល ថាវីក អាប់ឌុលហាក់ បានប្រគល់តួនាទីនេះទៅមេធាវីប្រឹក្សាអន្តរជាតិរបស់ព្រះរាជអាជ្ញាឈ្មោះ វ៉ាំងសង់ ដឺ វីលដ៏ ដេសម៉ែល ដើម្បីថ្លែងបន្ត។ ដេសម៉ែល បានធ្វើការកត់សម្គាល់ថា ក្រុមរបស់ នួន ជា បានប្រើប្រាស់ឈ្មោះរបស់សាក្សីកាលពីព្រឹកមិញជាជាងសំដៅទៅលើបុគ្គលដែលតុលាការដាក់ឈ្មោះក្លែងក្លាយសម្រាប់ហៅ ។ ក្រោយមក លោកបានស្នើថា អង្គជំនុំជម្រះគួរតែណែនាំក្រុមការពារក្តីរបស់ នួន ជា ថា មិនត្រូវធ្វើបែបនេះនៅថ្ងៃក្រោយទៀតទេ ។ លោក ដេសម៉ែល បានត្រលប់ទៅនិយាយអំពីរបាយការណ៍ដែលបានសរសេរឡើងតាមសំណើរបស់ក្រុមការពារក្តីរបស់ អៀង ធិរិទ្ធ ក្នុងឆ្នាំ២០០៩ ទាក់ទងទៅនឹងប្រភពព័ត៌មានសម្រាប់រកទីកន្លែងណាមួយ ។ លោកបានអះអាងថា របាយការណ៍នោះមានលក្ខណៈច្បាស់ហើយ ប្រធានបទដូចជាទីតាំងរបស់មន្ទីរសំខាន់ៗរបស់បក្សកុម្មុយនីស្តកម្ពុជា ក៏មានលក្ខណៈច្បាស់លាស់ណាស់ថា មានការពាក់ព័ន្ធទៅនឹងប្រធានបទអំពីរចនាសម្ព័ន្ធរដ្ឋបាលនៅក្នុងបក្សកុម្មុយនីស្តកម្ពុជា ។ ទីតាំងទាំងនេះរួមមានមន្ទីរ“ក-១” ដែលជាស្ថានីយរថភ្លើងនៅភ្នំពេញ និងពហុកីឡាដ្ឋានអូឡាំពិក ។

ក្រោយមក លោក ដេសម៉ែល រៀបរាប់អំពីរបាយការណ៍បន្ថែមទៀត និងបានអះអាងថា របាយការណ៍ទាំងអស់នេះសុទ្ធតែពាក់ព័ន្ធទៅនឹងរចនាសម្ព័ន្ធរដ្ឋបាលក្នុងបក្សកុម្មុយនីស្តកម្ពុជា ដូចជារបាយការណ៍មួយ ដែលរៀបរាប់អំពីជំរំពលកម្មការងារដែលសរសេរដោយអ្នករួចរស់ជីវិតម្នាក់ដែលធ្លាប់រស់នៅអស់រយៈពេលជិតបីឆ្នាំពេលដែលគាត់នៅជាកុមារ ហើយរបាយការណ៍មិនអាចកាត់ទុកថាមានភាពត្រឹមត្រូវទេព្រោះកាលនោះអ្នកនិពន្ធ គឺជាក្មេងម្នាក់ ។

លោក ដេសម៉ែល បានរក្សាជំហរថា ក្រុមការពារក្តីមិនបានអះអាងថា របាយការណ៍នោះអាចទុកចិត្តបាននិងមានភាពត្រឹមត្រូវឬអត់ទេ ដូច្នេះរបាយការណ៍នោះមិនគួរដាក់បញ្ចូលទេ ។ ក្រុមការពារក្តីក៏បានប្រើរបាយការណ៍នោះដើម្បីសួរសំណួរសាក្សីកាលពីមុនរួចមកហើយដែរ ។

លោកបានស្នើថា សំបុត្រឆ្លើយឆ្លង និងរបាយការណ៍ដែលបង្កើតដោយអ្នកស៊ើបអង្កេតរបស់អង្គជំនុំជម្រះ គួរតែត្រូវបានអនុញ្ញាតក្នុងការដាក់ជាសាក្សីដើម្បីផ្តល់ព័ត៌មានអំពីដើមបណ្តឹងរដ្ឋប្បវេណីជាក់លាក់និងសាក្សីណាមួយ ។ លោកបានបញ្ជាក់ដែរថា អង្គជំនុំជម្រះមានសិទ្ធិនឹងទទួល ឬជំទាស់របាយការណ៍នោះ តែលោកសុំស្នើថា ឯកសារនេះគួរតែទទួលយកដោយសារតែឯកសារ នេះបានផ្តល់ព័ត៌មានជាច្រើន ។ លោក ដេសម៉ែល ក៏បានស្នើដែរថា ឯកសារដែលទាក់ទងទៅនឹងបុគ្គលហើយមិនមាននៅក្នុងបញ្ជីរបស់សាក្សី គួរតែបញ្ចូលជាទម្រង់បន្ថែមភ័ស្តុតាងជាអត្ថបទ ។

ទាក់ទងទៅនឹងទំនាក់ទំនងអន្តរជាតិ លោក ដេសម៉ែល បានអះអាងថា ឯកសារនោះគួរតែទទួលយកហើយការជំទាស់របស់ក្រុមការពារក្តីទៅនឹងឯកសារមួយចំនួនគឺមិនពិតទេ ហើយនេះគ្រាន់តែជាការតវ៉ាប៉ុណ្ណោះ ។ ឧទាហរណ៍ដូចជា ប្រវត្តិរូបផ្ទាល់ខ្លួនរបស់ កែ ពក ដែលមិនត្រូវបានចាត់ថ្នាក់ជារបាយការណ៍ឬទំនាក់ទំនងជាអន្តរជាតិទេ ។ លោកបានពន្យល់ថា ប្រភពនៃប្រភេទផ្សេងៗនៃទំនាក់ទំនងអន្តរជាតិដូចជាទូរលេខរបស់រដ្ឋាភិបាលបារាំង និងសហរដ្ឋអាមេរិកជាដើម ។ លោក ដេសម៉ែល បញ្ជាក់ថា ឯកសារបែបនេះមិនគួរដាក់បញ្ចូលទេ ដោយសារតែឯកសារទាំងអស់មិនមានមូលដ្ឋានច្បាស់លាស់និងមិនបានបញ្ជាក់ពីយថាភាព ។

ទាក់ទងទៅនឹងខ្លឹមសាររបស់ទូរលេខជាក់លាក់មួយចំនួន លោក ដេសម៉ែល បានកត់ចំណាំថា ឯកសារ ទូរលេខខ្លះរៀបរាប់អំពីរបៀបដែលថ្នាក់ដឹកនាំបក្សកុម្មុយនីស្តកម្ពុជាត្រូវបានជូនដំណឹងទាក់ទងទៅនឹង ស្ថានភាពនៅពេលដែលជនបរទេសបានប្រមូលផ្តុំគ្នានៅស្ថានទូតបារាំងនៅពេលដែលខ្មែរក្រហមទទួលបានជ័យជម្នះនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។

លោកបានបញ្ជាក់ថា ក្រុមការពារក្តីរបស់ ខៀវ សំផន ក៏បានប្រើសារទូរលេខមួយចំនួនដែរ ទោះបីជាខ្លួនជំទាស់ទៅនឹងសារទូរលេខក៏ដោយ ហើយធ្លាប់បាននិយាយថា ឯកសារបែបនោះមានប្រយោជន៍ណាស់ ។ លោក ដេសម៉ែល បានផ្តល់ឧទាហរណ៍អំពីសាទូរលេខមួយចំនួន ហើយគាត់បានពន្យល់អំពីខ្លឹមសារនៅក្នុងឯកសារទាំងនេះដែលនិងត្រូវយកមកប្រើប្រាស់ ។ លោកក៏បានរៀបរាប់អំពីប្រភេទជារួមនៃឯកសារ ។ ឧទាហរណ៍មួយគឺសារទូរលេខពីទីក្រុងប៉េកាំង ប្រទេសចិន សារទូរលេខរបស់អ្នកការទូតមួយក្រុមរួមមាន អៀង សារី និង អៀង ធិរិទ្ធ ដើម្បីជួបជាមួយគណៈប្រតិភូពីប្រទេសផ្សេងទៀត រួមមានប្រទេសអាហ្វ្រិកទាំងប្រាំពីរ ។ លោក ដេសម៉ែល បានពន្យល់អំពីអ្វីដែលសាក្សីនិងឯកសារផ្សេងទៀតបានបញ្ជាក់ថា ដំណើរទស្សនៈកិច្ចនោះបានកើតឡើងមែន ។ សារទូរលេខផ្សេងទៀតដែលបានពិភាក្សា គឺការចាប់ខ្លួន សិរិមតៈ នៅខាងក្រៅស្ថានទូតបារាំងកាលនៅថ្ងៃទី២០

ខែមេសា ឆ្នាំ ១៩៧៥ ។ ជាថ្មីម្តងទៀត លោក ដេសម៉ែល បានរៀបរាប់អំពីខ្លឹមសារនៃសារទូរលេខនេះដែលទាក់ទងជាមួយនឹងភស្តុតាងផ្សេងទៀតដែលរៀបរាប់នៅព្រឹត្តិការណ៍តែមួយ ។

បន្ទាប់ពីពិភាក្សាអំពីឯកសាររបស់រដ្ឋាភិបាលបារាំង លោក ដេសម៉ែល បានត្រលប់ទៅពិភាក្សាអំពីទំនាក់ទំនងជាមួយអាមេរិក ដែលរៀបរាប់ចាប់ពីកិច្ចប្រជុំការិយាល័យនៅមូលដ្ឋានរហូតដល់កំណត់ហេតុកិច្ចប្រជុំនៅសេតវិមាន ។ លោកក៏បានពន្យល់ពីរបៀបដែលអង្គជំនុំជម្រះទទួលបានឯកសារទាំងនេះ និងបានអះអាងថា ព្រោះឯកសាររបស់អាមេរិកទាំងអស់ឥឡូវនេះត្រូវបានដាក់ឲ្យសាធារណជនមើលបាន ភាពពិតរបស់ឯកសារនោះអាចស្មានបានថាមានភាពច្បាស់លាស់ហើយ ដែលផ្ទុយទៅនឹងអ្វីដែលហៅថា ភស្តុតាងមិនច្បាស់លាស់ ។ ទាក់ទងទៅនឹងប្រធានបទនៅក្នុងឯកសារនេះ លោក ដេសម៉ែល បានបញ្ជាក់ថា ឯកសារអាមេរិករៀបរាប់ពីព្រឹត្តិការណ៍សំខាន់ៗដូចជាការជម្លៀសទីក្រុងភ្នំពេញ និងរចនាសម្ព័ន្ធរដ្ឋបាលក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ រចនាសម្ព័ន្ធនិងរូបរាងរបស់ឯកសារនោះពិតជាមានឃថាភាព ។

ត្រង់ចំណុចនេះ លោក ដេសម៉ែល បានបញ្ចប់ដោយសារតែដល់ម៉ោងកំណត់ហើយ និងបានជូនដំណឹងទៅអង្គជំនុំជម្រះថា លោកមានគម្រោងនឹងបញ្ចប់សេចក្តីថ្លែងរបស់ខ្លួននៅព្រឹកស្អែក ។ មុននឹងបញ្ចប់សម្រាប់ថ្ងៃនេះ អេគ្រូ អ៊ីនូហ្ស៊ី មេធាវីការពារក្តីរបស់ នួន ជា បានក្រោកឈរហើយនិយាយថា ក្រុមការពារក្តីមិនមានពេលវេលាដើម្បីឆ្លើយតបទៅនឹងព្រះរាជអាជ្ញា និងភាគីដើមបណ្តឹងរដ្ឋប្បវេណីវិញទេ ទាក់ទងទៅនឹងឯកសារនោះ ។ មេធាវីបានស្នើជាផ្លូវការថា ខ្លួនគួរតែមានឱកាស ដើម្បីឆ្លើយតបទៅនឹងព្រះរាជអាជ្ញានិងភាគីដើមបណ្តឹងរដ្ឋប្បវេណី ។ ក្រុមការពារក្តីរបស់ អៀង សារី និង ខៀវ សំផន មិនបានចូលរួមធ្វើសំណើដូចគ្នានេះទេ ។

លោក ដេសម៉ែល បានឆ្លើយតបតំណាងឲ្យព្រះរាជអាជ្ញាថា តាមលោកយល់ ក្រុមការពារក្តីនិងត្រូវបានផ្តល់ពេលវេលានៅថ្ងៃចន្ទ ទី១៩ ខែមិនា ដើម្បីឆ្លើយតប ។ លោកក៏បានសួរថាតើកាលវិភាគក្រោយៗទៀតគួរតែដំណើរការឲ្យបានលឿនជាងសប្តាហ៍នេះបានដែរឬទេ?

ចៅក្រមរបស់អង្គជំនុំជម្រះពិភាក្សាគ្នាមួយសន្ទុះ ហើយក្រោយមក ចៅក្រម និល ណុន បានបញ្ជាក់ថា ភាគីការពារក្តីទាំងបីក្រុមនឹងផ្តល់ពេលវេលារួមចំនួនមួយម៉ោងដើម្បីឆ្លើយតបទៅនឹងអ្វីដែលភាគីព្រះរាជអាជ្ញានិងដើមបណ្តឹងរដ្ឋប្បវេណីលើកឡើង ។ ចៅក្រម និល ណុន បានបញ្ជាក់ទៀតថា ភាគីការពារក្តី អាចឆ្លើយបាននៅពេលដែលភាគីដើមបណ្តឹងរដ្ឋប្បវេណីបញ្ចប់សេចក្តីថ្លែងការណ៍របស់ខ្លួនទៅនឹងការជំទាស់របស់ភាគីការពារក្តី ។ ទាក់ទងទៅនឹងដំណើរការពេលក្រោយៗទៀត ចៅក្រម និល ណុន បានបញ្ជាក់ថា អង្គជំនុំជម្រះនឹងប្រកាន់ភ្ជាប់នូវកាលវិភាគដែលបានកំណត់រួចហើយ តែត្រូវរំកិល

*ទៅមុខមួយថ្ងៃ ដូចជា សក្ខីកម្មរបស់ នួន ជា និង កាំង ហ្កេចអ៊ាវ ហៅ ឌុច នឹងប្តូរពីថ្ងៃអង្គារ៍ ទី២០ មកថ្ងៃចន្ទ ទី១៩ ខែមីនា វិញ ។*

*ដំណើរការសវនាការនឹងចាប់ផ្តើមនៅថ្ងៃស្អែកវេលាម៉ោង៩ៈ០០ ហើយនឹងនិយាយពីការបញ្ចប់ការឆ្លើយតបរបស់ភាគីព្រះរាជអាជ្ញាទៅនឹងការជំទាស់របស់ភាគីការពារក្តី ។*

**-ចប់-**